ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# បំណិនជីវិតតាមមូលដ្ឋាន

សម្រាប់

## កម្រិតបឋមសិក្សា

២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៥០៥ អយក.ប្រក

# ប្រកាស
# ស្ដីពី
# ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សា**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សានេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សាជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានបឋមសិក្សា ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតបឋមសិក្សា បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតបឋមសិក្សា សំដៅបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នកសិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្ត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីសម្ខាន់ក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។ [illegible]

ថ្ងៃ [illegible] ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលការអប់រំបំណិនជីវិតដែលជាមុខវិជ្ជាគោលដូចមុខវិជ្ជាដទៃទៀតដែរ ទៅក្នុងកម្មវិធីសិក្សាជាតិនៅកម្រិតបឋមសិក្សាចាប់ពីថ្នាក់ទី៤ដល់ទី៦។

ឯកសារកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សាត្រូវបានរៀបចំឡើងទាក់ទងទៅនឹងប្រធានបទដែលជាតម្រូវការរបស់មូលដ្ឋាន។ កម្មវិធីសិក្សានេះរួមមាន ប្រធានបទដែលទាក់ទងនឹងកសិកម្ម សេវាកម្ម សិប្បកម្មខ្នាតតូច សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងបញ្ហាសង្គម។ ឯកសារនេះជាមូលដ្ឋានជួយដល់គណៈគ្រប់គ្រងសាលា គ្រូបង្រៀនក្នុងការជ្រើសរើសប្រធានបទ រៀបចំកាលវិភាគវិធីសាស្ត្របង្រៀន និងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន នៅថ្នាក់ទី៤ ទី៥ និងទី៦ ប្រកបដោយប្រសិទ្ធភាពនិងមាននិរន្តរភាពព្រមទាំងផ្តល់ឱកាសឱ្យសិស្សានុសិស្សក្នុងការអភិវឌ្ឍបំណិនដើម្បីរស់នៅក្នុងសង្គម។

អនុគណៈកម្មការមុខវិជ្ជាឯកទេសបំណិនជីវិតតាមមូលដ្ឋាន រង់ចាំទទួលរាល់មតិយោបល់កែលម្អពីគ្រប់មជ្ឈដ្ឋានដើម្បីរួមចំណែកក្នុងការធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាលម្អិតនេះកាន់តែមានប្រសិទ្ធភាពខ្ពស់។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសបំណិនជីវិតតាមមូលដ្ឋាន**

# មាតិកា


| | | |
|---|---|---|
| ប្រកាស | | i |
| បុព្វកថា | | iii |
| អារម្ភកថា | | iv |
| មាតិកា | | v |
| ១- | សេចក្តីផ្តើម | 1 |
| ២- | គោលបំណង | 2 |
| ៣- | គោលគំនិតៗសំខាន់ៗ | 2 |
| ៤- | របាយម៉ោងសិក្សា | 4 |
| ៥- | ការណែនាំអនុវត្ត | 4 |
| ៦- | ការវាយតម្លៃ | 7 |
| ៧- | តារាងកម្មវិធីសិក្សា | 12 |
| ៧.១- | លទ្ធផលរំពឹងទុកថ្នាក់ទី៤ | 12 |
| ៧.២- | លទ្ធផលរំពឹងទុកថ្នាក់ទី៥ | 14 |
| ៧.៣- | លទ្ធផលរំពឹងទុកថ្នាក់ទី៦ | 17 |
| ៧.៤- | កម្មវិធីសិក្សាលម្អិតថ្នាក់ទី៤ | 19 |
| ៧.៥- | កម្មវិធីសិក្សាលម្អិតថ្នាក់ទី៥ | 29 |
| ៧.៦- | កម្មវិធីសិក្សាលម្អិតថ្នាក់ទី៦ | 36 |
| ៨- | ឯកសារយោង | 45 |
| ៩- | បញ្ជីឈ្មោះគណៈកម្មការ | 46 |

## ១- សេចក្តីផ្តើម

ប្រទេសជាច្រើនលើសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរ កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្រៀនបំណិនជីវិត ដើម្បីឱ្យអ្នកសិក្សាមានចំណេះដឹង បំណិន ដើម្បីអភិវឌ្ឍខ្លួនឱ្យក្លាយជាពលរដ្ឋល្អ ពលករជំនាញ ពលរដ្ឋពេញលេញ និងចេះរស់នៅជាមួយគ្នា។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ក្នុងនោះបានបញ្ចូលការអប់រំបំណិនជីវិតជាមុខវិជ្ជាគោលដូចមុខវិជ្ជាដទៃទៀតដែរ។
សម្រាប់បឋមសិក្សាបានកំណត់ឱ្យបង្រៀន២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ដែល១ម៉ោងសិក្សាមានរយៈពេល៤០នាទី។

ដើម្បីឆ្លើយតបទៅនឹងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្របខណ្ឌកម្មវិធីសិក្សាអប់រំបំណិនជីវិតតាមមូលដ្ឋាន និងអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ដែលអាចអនុវត្តបានទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

បំណិនមូលដ្ឋានត្រូវបង្រៀនដល់អ្នកសិក្សាទាំងអស់ ដោយបញ្ជ្រាបក្នុងមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្រ្ត និងសិក្សាសង្គម ចាប់ពីថ្នាក់ទី១ដល់ទី១២ ។

បំណិនអាជីពជាបំណិនទាំងឡាយណា ដែលផ្តោតលើសមត្ថភាពវិជ្ជាជីវៈជាក់ស្តែង ហើយចែកជាបីផ្នែកទៀត គឺបំណិនមូលដ្ឋាន សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ និង បំណិនបច្ចេកទេស។ បំណិនទាំងនេះបង្រៀននៅក្នុងកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ពីថ្នាក់ទី៤ ដល់ថ្នាក់ទី៩ ហើយការអប់រំបច្ចេកទេសបង្រៀននៅក្នុងកម្មវិធីសិក្សាអប់រំបច្ចេកទេស ថ្នាក់ទី១០ ទី១១ និងទី១២។

ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់លទ្ធភាពដល់សាលារៀន ក្នុងការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ។ ក្នុងការអនុវត្តជាក់ស្តែង សាលារៀនជួបការលំបាកជាច្រើន ហើយសមត្ថភាពយល់ដឹងរបស់គ្រូចំពោះកម្មវិធីសិក្សាបំណិនជីវិតនៅមានកម្រិត។ បញ្ហាប្រឈមក្នុងការអនុវត្តនេះបណ្តាលមកពី ការខ្វះគ្រូឯកទេសបំណិនជីវិត ខ្វះថវិកា ខ្វះកម្មវិធីសិក្សា និងខ្វះសៀវភៅសិក្សា។

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍឯកសារមួយចំនួនសម្រាប់ការអប់រំបំណិនជីវិតដូចជា៖

- ឯកសារណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន សម្រាប់សាលារៀន សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល គឺជាឯកសារជំនួយដល់អ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ដោយបានបង្ហាញពីរបៀបនៃការអនុវត្តនៅឆ្នាំ២០០៦។
- ឯកសារកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន គឺជាឯកសារជំនួយដល់គ្រូបង្រៀនបំណិនជីវិតដែលមាន ២០ម៉ូឌុល ជាឧទាហរណ៍សម្រាប់ការជ្រើសរើសនៅឆ្នាំ២០០៦។
- ឯកសារណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាន បានបកស្រាយលំនាំបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋានលើមេរៀនស្តីពីការដាំដុះ និងចិញ្ចឹម ដើម្បីឱ្យសិស្សក្លាយជាអ្នកផលិត។
- ឯកសារណែនាំគ្រូការអប់រំបំណិនជីវិតតាមមូលដ្ឋាន ចេញផ្សាយដោយនាយកដ្ឋានមធ្យមសិក្សា ឆ្នាំ២០១៥។ ចាប់ពីឆ្នាំ២០២០តទៅ ក្រសួងអប់រំ យុវជន និងកីឡានឹងអភិវឌ្ឍឯកសារបន្ថែមទៀត ដើម្បីជាជំនួយដល់សាលារៀនក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ដូចជា៖
- កម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សា
- សៀវភៅសម្រាប់សិស្ស និងសៀវភៅសម្រាប់គ្រូ
- សម្ភារៈបង្រៀននិងរៀន និងសម្ភារឧបទេស។ល។

## ២- គោលបំណង

គោលបំណងនៃការសិក្សាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានគឺធានាឱ្យសិស្សមាន៖

- **វិជ្ជាសម្បទា** : ស្វែងយល់ពីបញ្ហាសង្គម និងបទពិសោធពាក់ព័ន្ធទៅនឹងប្រពៃណី សង្គមកិច្ច សុខភាព បរិស្ថាន ព្រមទាំងអាជីពងាយៗដែលមានក្នុងមូលដ្ឋាន។
- **បំណិនសម្បទា** : អនុវត្តចំណេះដឹង ការច្នៃប្រឌិតបង្កើតថ្មី ទំនាក់ទំនងល្អ ការសម្រេចចិត្ត និងដំណោះស្រាយបញ្ហាខ្លួនឯង គ្រួសារ និងសង្គមប្រកបដោយប្រសិទ្ធភាព។
- **ចរិយាសម្បទា** : បណ្ដុះការគិតបែបវិជ្ជមាន អធ្យាស្រ័យល្អ ស្មោះត្រង់ គ្រប់គ្រងខ្លួនឯង និងលើកស្ទួយសុខមាលភាពខ្លួនឯង គ្រួសារ សង្គមប្រកបដោយភាពសុខដុមរមនា។

បំណិនជីវិតតាមមូលដ្ឋាន ជាមុខវិជ្ជាមួយដែលផ្ដល់ឱ្យអ្នកសិក្សាមានឱកាសក្នុងការទទួលបានផ្នែកចំណេះដឹង បំណិន និងការអនុវត្តតាមរយៈការចូលរួមលើកកម្ពស់ជីវភាពគ្រួសារ និងសង្គម។

កម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានមានសមាសភាគដូចខាងក្រោម៖

១- កសិកម្ម

២-សេវាកម្ម

៣-សិប្បកម្ម

៤-សហគ្រិនភាព និងភាពជាអ្នកដឹកនាំ

៥-បញ្ហាសង្គម

## ៣- គោលគំនិតសំខាន់ៗ

### ៣.១- បំណិនមូលដ្ឋាន

បំណិនមូលដ្ឋានជាបំណិនចាំបាច់ដែលអ្នកសិក្សាគ្រប់រូបត្រូវតែទទួលបានដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ការរស់នៅ។ បំណិនមូលដ្ឋានរួមមាន ចំណេះដឹងទូទៅ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនការងារ និងគុណតម្លៃផ្ទាល់ខ្លួន។ បំណិនមូលដ្ឋាននេះត្រូវបានបញ្ជ្រាបទៅក្នុងមុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម។

### ៣.២- បំណិនបច្ចេកទេស

- **ផ្នែកកសិកម្ម**
  - ការរៀបចំសួនជីវៈចម្រុះ ការបណ្ដុះកូនឈើ ការផលិតជីកំប៉ុស្ត...
  - ដំណាំផ្លែ: ត្រប់ ត្រសក់ ល្ពៅ ល្ហុង ម្ទេសហាវ៉ៃ ម្រះ ពោត សណ្ដែកបាយ ឪឡឹក សណ្ដែកគួរ សណ្ដែកបារាំង ត្រឡាច ប៉េងប៉ោះ ននោង...
  - ដំណាំដើម និងស្លឹក: ត្រកួន ស្ពៃក្រញ៉ាញ់ ស្ពៃចង្កឹះ អំពៅ ស្ពៃខៀវ ស្ពៃជើងទា ស្ពៃក្ដោប ស្ពៃផ្កា ខ្ទឹមស្លឹក សណ្ដែកបណ្ដុះ ខាត់ណា ផ្សិតចំបើង សាលាដ អំពៅ...
  - ដំណាំមើម : ដៃថាវ ដំឡូងជ្វា ដំឡូងមី ខ្ទឹមបារាំង...
  - ការចិញ្ចឹមសត្វ : មាន់ ជន្លេន ត្រី ទា ជ្រូក ទន្សាយ គោ ពពែ កង្កែប អន្ទង់...

- **ផ្នែកសិប្បកម្មខ្នាតតូច:** មេរៀនសិប្បកម្មខ្នាតតូច ការផលិតស្រោមសំបុត្រ ចង់ក្រដាស ការបត់ក្រដាសបង្កើតជារូបផ្សេងៗ ការសូនរូបវត្ថុអនុស្សាវរីយ៍ពីដីឥដ្ឋ ការត្បាញក្រដាសពណ៌ ទ្រនាប់កែវ ទ្រនាប់ចាន ការផលិតវត្ថុអនុស្សាវរីយ៍ជាវត្ថុផ្សេងៗអំពី វល្លិ រំពាក់ សំបកខ្យង ខ្ចៅ ឬស្លឹកត្នោត ក្រដាសពណ៌ ឬកំណាត់...
- **ផ្នែកសេវាកម្ម** : សេវាកម្ម ការលក់វត្ថុអនុស្សាវរីយ៍ ការលក់ទំនិញ តំណាប់ចេក តំណាប់អម្ពិលទុំ ត្រីងៀត ការ៉េម ការរៀបចំសណ្តាប់ធ្នាប់ក្នុងគេហដ្ឋាន និងថ្នាក់រៀន ការបង្ហាញផ្លូវភ្ញៀវ ការរៀបចំផ្កាដាក់ថូ ឬត្រក បដិសណ្ឋារកិច្ច ជ្រក់សណ្តែកបណ្តុះ...

### ៣.៣- សហគ្រិនភាព និងភាពជាអ្នកដឹកនាំ

- **សហគ្រិនភាព** : គឺជាដំណើរការនៃការបើកអាជីវកម្មថ្មីមួយដែលដំបូងជាអាជីវកម្មតូចមួយសម្រាប់ផ្តល់ជូននូវផលិតផលមួយ ឬសេវាសម្រាប់លក់ឬដូរ។ ប្រធានបទដែលទាក់ទងនឹងសហគ្រិនភាពមាន ការសន្សំប្រាក់ ការចង់បាននិងតម្រូវការ ផែនការហិរញ្ញវត្ថុ កម្ចីប្រាក់ មូលដ្ឋានគ្រឹះនៃការបង្កើតមុខរបរ ផែនការផ្ទាល់ខ្លួន គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ចំណូលចំណាយ ការធ្វើផែនការការងារ ការរៀបចំផែនការដើម្បីអនាគត ការបង្កើតមុខរបរងាយៗ...។
- **ភាពជាអ្នកដឹកនាំ** : គឺជាអ្នកដែលមានអនុភាព ឬឥទ្ធិពលទៅលើបុគ្គល ឬបណ្តុះចិត្តអ្នកនៅជុំវិញខ្លួនឱ្យសកម្មក្នុងក្រុមឬអង្គភាព ហើយជួយពួកគេ (បុគ្គលនិងក្រុមនោះ) ឱ្យបង្កើតគោលដៅ និងនាំពួកគេឆ្ពោះទៅសម្រេចគោលដៅ គាំទ្រអ្នកដែលស្វែងរកឱ្យមានការផ្លាស់ប្តូរតាមដានពីស្ថានភាពនៅជុំវិញ និងធ្វើឱ្យពួកគេកាន់តែមានប្រសិទ្ធភាព។ ប្រធានបទដែលទាក់ទងភាពជាអ្នកដឹកនាំមានការប្រាស្រ័យទាក់ទង ការរៀបចំផែនការសម្រាប់អនាគត ការធ្វើកំណត់ត្រាផ្ទាល់ខ្លួនប្រចាំថ្ងៃ ការរៀបចំកិច្ចប្រជុំ ការសរសេរសុន្ទរកថា ការកាន់កម្មវិធី ការធ្វើផែនការការងារ ការលើកទឹកចិត្ត ការសម្របសម្រួល...។

### ៣.៤- បញ្ហាសង្គម

- ផ្នែកសង្គមមានដូចជា ខ្ញុំជានរណា ស្លាកសញ្ញាចរាចរណ៍ ការលើកទឹកចិត្ត ការជួយមិត្ត អាហារូបត្ថម្ភ ខ្ញុំដឹងពីសិទ្ធិរបស់ខ្ញុំ យេនឌ័រ ការចងក្រងក្រុម ការពេញចិត្តចំពោះរាងកាយរបស់ខ្ញុំ ការស្តាប់ និងការរៀន អំពើហិង្សាក្នុងគ្រួសារ បំណុលវណ្ឌក គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ គ្រោះមហន្តរាយ ...។

## ៤- របាយម៉ោងសិក្សា

ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសបានកំណត់ឱ្យបង្រៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ចំនួន៣៥សប្តាហ៍ក្នុងមួយឆ្នាំសិក្សា។

របាយម៉ោងសិក្សាបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សា ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| ថ្នាក់ទី | ចំនួនម៉ោងក្នុងកម្មវិធីសិក្សា |
|---|---|
| ៤ | – ១ឆ្នាំសិក្សា៖ ២ម៉ោងសិក្សា x ៣៥សប្តាហ៍ =៧០ម៉ោងសិក្សា<br>– ១សប្តាហ៍៖ ២ម៉ោងសិក្សា<br>– ១ម៉ោងសិក្សាមានរយៈពេល ៤០នាទី |
| ៥ | – ១ឆ្នាំសិក្សា៖ ២ម៉ោងសិក្សា x ៣៥សប្តាហ៍ = ៧០ម៉ោងសិក្សា<br>– ១សប្តាហ៍៖ ២ម៉ោងសិក្សា<br>– ១ម៉ោងសិក្សាមានរយៈពេល ៤០នាទី |
| ៦ | – ១ឆ្នាំសិក្សា៖ ២ម៉ោងសិក្សា x ៣៥សប្តាហ៍ = ៧០ម៉ោងសិក្សា<br>– ១សប្តាហ៍៖ ២ម៉ោងសិក្សា<br>– ១ម៉ោងសិក្សាមានរយៈពេល ៤០នាទី |

## ៥- ការណែនាំអនុវត្ត

ឯកសារកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន និងការណែនាំអនុវត្តត្រូវបានកសាងឡើងដើម្បី៖

- បង្កភាពងាយស្រួលដល់សាលារៀនក្នុងការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ឱ្យឆ្លើយតបតាមតម្រូវការជាក់ស្តែងនៃមូលដ្ឋាន
- ផ្តល់ការណែនាំអំពីរបៀបជ្រើសរើសមេរៀន និងរបៀបនៃការរៀបចំប្រធានបទសិក្សា ដែលមិនមាននៅក្នុងកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាននេះ
- ផ្តល់នូវលំនាំនៃវិធីសាស្ត្របង្រៀននិងរៀន និងវាយតម្លៃ
- លើកទឹកចិត្តអ្នកពាក់ព័ន្ធឱ្យផ្តោតការយកចិត្តទុកដាក់ចំពោះតម្រូវការដែលមាននៅក្នុងសហគមន៍ និងចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ។

ដើម្បីសម្រេចគោលបំណង និងធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាននៅកម្រិតបឋមសិក្សាទទួលបានជោគជ័យ គោលការណ៍មួយចំនួនត្រូវបានអនុវត្តរួមមាន៖

១- ការបង្រៀនគឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស ដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្រ គោលវិធីសិស្សមជ្ឈមណ្ឌល ឬវិធីចម្រុះ

២- ការបង្រៀនគឺជាសកម្មភាពជួយលើកទឹកចិត្តសិស្ស ឱ្យចេះរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ ឆ្លើចារ និងអនុវត្តចំណេះដឹងសម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់វិធីសាស្ត្រទំនើប ដូចជាសហការ សង្កេត និងគម្រោង

៣- ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សា

៤- ការបង្រៀនត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេស រួមទាំងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្បូរបែប និងមានបច្ចុប្បន្នភាព។

ដើម្បីអនុវត្តគោលការណ៍នេះឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល លោកគ្រូ អ្នកគ្រូត្រូវទទួលបានការពង្រឹងសមត្ថភាពរយៈពេលខ្លី និងការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូលើគោលការណ៍រៀននិងបង្រៀន

និងវាយតម្លៃ។ វិធីសាស្ត្របង្រៀននិងរៀនត្រូវបានអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល ដោយប្រើវិធីសាស្ត្រការសិក្សាតាមបែបរិះរក ការសិក្សាផ្អែកលើបញ្ហា ការសិក្សាតាមបែបគម្រោង ការសិក្សាតាមបែបចម្រុះ និងការសិក្សាបែបពិគ្រោះយោបល់ ឬការហាត់ការ ។

### ៥.១- ការជ្រើសរើសប្រធានបទ

ដើម្បីរៀបចំប្រធានបទសម្រាប់មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន នាយកសាលា និងគ្រូបង្រៀនត្រូវរៀបចំជ្រើសរើសប្រធានបទតាមគោលការណ៍ដូចខាងក្រោម៖

- **សម្រាប់សាលាបឋមសិក្សាត្រូវបង្រៀន២ម៉ោង/សប្តាហ៍**

| របាយម៉ោងសម្រាប់បឋមសិក្សា(ថ្នាក់ទី៤ដល់ទី៦) | | | |
|---|---|---|---|
| **ល.រ** | **ប្រធានបទសិក្សា** | **ចំនួនម៉ោងក្នុង១សប្តាហ៍** | **ចំនួនសប្តាហ៍** |
| ១ | កសិកម្ម | ១ | ៣៥ |
| ២ | សេវាកម្ម | | |
| ៣ | សិប្បកម្ម | | |
| ៤ | បញ្ហាសង្គម | | |
| ៥ | សហគ្រិនភាព និងភាពជាអ្នកដឹកនាំ | ១ | |
| | សរុបម៉ោង/សប្តាហ៍ | ២ម៉/សប្តាហ៍ | ៣៥សប្តាហ៍ |

- **សាលារៀនអាចជ្រើសរើសដូចខាងក្រោម៖**

**ក. ជម្រើសទី១**

- បំណិនបច្ចេកទេស បង្រៀន៣៥ម៉ោងក្នុង១ឆ្នាំ
- បំណិនសហគ្រិនភាព និងភាពជាអ្នកដឹកនាំ បង្រៀន៣៥ម៉ោងក្នុង១ឆ្នាំ

**ខ. ជម្រើសទី២**

- បញ្ហាសង្គម បង្រៀន៣៥ម៉ោងក្នុង១ឆ្នាំ
- បំណិនសហគ្រិនភាព និងភាពជាអ្នកដឹកនាំ បង្រៀន៣៥ម៉ោងក្នុង១ឆ្នាំ

**គ. ជម្រើសទី៣**

- បំណិនបច្ចេកទស និងបញ្ហាសង្គម បង្រៀន៣៥ម៉ោងក្នុងមួយឆ្នាំ
- បំណិនសហគ្រិនភាព និងភាពជាអ្នកដឹកនាំ បង្រៀន៣៥ម៉ោងក្នុង១ឆ្នាំ

ក្នុងករណីដែលសាលារៀនពុំបានជ្រើសរើសប្រធានបទណាមួយនៅក្នុងផ្នែកកសិកម្ម សិប្បកម្ម សេវាកម្ម និងបញ្ហាសង្គម ដែលមាននៅក្នុងកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន សាលារៀនអាចជ្រើសរើសប្រធានបទផ្សេងៗដែលសមស្របតាមមូលដ្ឋានយកមកបង្រៀនបាន។ ការអនុវត្តវិធីសាស្ត្របង្រៀន និងការវាយតម្លៃ គ្រូត្រូវអនុវត្តតាមលំនាំដូចខាងលើ។

### ៥.២- គោលវិធី និងវិធីសាស្ត្របង្រៀន

### គោលវិធីបង្រៀន

ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្រៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ឱ្យទទួលបានលទ្ធផលតាមការគ្រោងទុកនៃមេរៀននីមួយៗ គោលវិធីមួយចំនួនត្រូវបានយកមកអនុវត្ត រួមមាន៖

១- ប្រជុំគណៈគ្រប់គ្រងសាលាដើម្បីកំណត់អាទិភាពនៃមេរៀនតាមជំពូកនីមួយៗសម្រាប់កម្រិតថ្នាក់ដែលមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា អាជ្ញាធរដែនដី សហគមន៍ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស

២- សិក្សាពីតម្រូវការសិក្សារបស់សិស្ស ដោយផ្តល់អាទិភាពលើភាគរយខ្ពស់នៃការចង់បានរបស់សិស្ស

៣- អនុវត្តវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល គឺការសិក្សាតាមបែបរិះរក ការសិក្សាផ្អែកលើបញ្ហា ការសិក្សាតាមបែបគម្រោង និងការសិក្សាតាមបែបចម្រុះ។

### វិធីសាស្ត្របង្រៀន

ដើម្បីសម្រេចបានគោលវិធីទាំងនេះ លំនាំនៃការបង្រៀននិងរៀនបំណិនជីវិតត្រូវអនុវត្តដូចតទៅ៖

១- **ការសិក្សាស្រាវជ្រាវតាមបែបរិះរក**: ជាការសិក្សាតាមរយៈការប្រមូលព័ត៌មាន ការចងក្រងព័ត៌មាន វិភាគ បកស្រាយ និងវាយតម្លៃព័ត៌មានដោយមានឯកសារតម្កល់ស្នាដៃត្រឹមត្រូវ និងមានគំនិតផ្តួចផ្តើមរៀបចំផែនការដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគេ។

២- **ការសិក្សាជាក្រុម**: ជាការសិក្សាដែលត្រូវបានបង្កើតឡើងដើម្បីឱ្យមានការចូលរួមយ៉ាងសកម្ម ព្រមទាំងចែករំលែកបទពិសោធ និងចំណេះដឹងទៅវិញទៅមក។

៣- **ការសិក្សាតាមបែបគម្រោង** : គឺជាការសិក្សាតាមរយៈការបង្កើតលទ្ធផល និងបកស្រាយពន្យល់លទ្ធផល។

៤- **ការសិក្សាតាមបែបចម្រុះ**: ជាការសិក្សាដោយប្រើវិធីផ្សេងៗជាច្រើនក្នុងការបង្រៀន និងតម្រូវទៅតាមស្ថានភាពជាក់ស្តែង។

៥- **ការសិក្សាបែបពិគ្រោះយោបល់ ឬការហាត់ការ :**

ជាវិធីសាស្ត្រមួយផ្សេងទៀតដែលអាចឱ្យសិស្សរៀនក្នុងរូបភាពជាការហាត់ការ ទៅតាមលំនាំដូចខាងក្រោម៖

- ស្វែងយល់ពីប្រធានបទដែលត្រូវរៀន អាចជាបញ្ហាសង្គម ឬអាជីពងាយ
- ប្រមូលព័ត៌មាន និងបទពិសោធពីសហគមន៍លើប្រធានបទដែលត្រូវរៀន
- វិភាគព័ត៌មានដើម្បីរកដំណោះស្រាយ
- អភិវឌ្ឍផែនការសកម្មភាពងាយៗដែលសិស្សដឹកនាំ ដោយមានការចូលរួមពីសហគមន៍
- អនុវត្តផែនការសកម្មភាពនៅតាមសហគមន៍ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន
- ឆ្លុះបញ្ចាំង និងវាយតម្លៃលើការបង្រៀននិងរៀនលើប្រធានបទ។

គ្រូបង្រៀនត្រូវបានទទួលការបណ្តុះបណ្តាល និងបានអនុវត្តជាក់ស្តែងផ្ទាល់ខ្លួនជាមុន ដើម្បីជ្រើសរើសយកវិធីសាស្ត្រណាមួយយកមកអនុវត្តចំពោះការបង្រៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដែលបង្កលក្ខណៈឱ្យសិស្សអនុវត្តច្រើនជាងទ្រឹស្តី។

## ៦- ការវាយតម្លៃ

ការវាយតម្លៃសិស្សក្នុងការរៀនបំណិនជីវិតផ្ដោតលើទិដ្ឋភាពបីយ៉ាង៖

- **ការអភិវឌ្ឍវិជ្ជាសម្បទា**

ជាការវាយតម្លៃដែលផ្ដោតលើខ្លឹមសារជាក់លាក់ ដែលជួយអ្នកសិក្សាឱ្យសម្រេចចិត្តបានត្រឹមត្រូវដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយក្នុងប្រធានបទសិក្សា។ លក្ខណៈវិនិច្ឆ័យវាយតម្លៃនឹងផ្ដោតលើចំណេះដឹងដែលទទួលបានការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង និងការប្រើប្រាស់ចំណេះដឹងសម្រាប់គ្រួសារ និងសហគមន៍។

- **ការអភិវឌ្ឍបំណិនសម្បទា**

ការវាយតម្លៃនេះផ្ដោតលើបំណិនដែលបានសិក្សា ដោយជ្រើសរើសក្នុងចំណោមបំណិនបុរេវិជ្ជាជីវៈការគ្រប់គ្រងអាជីវកម្មនិងការងារ និងបច្ចេកទេសទៅតាមប្រធានបទ និងតម្រូវការរបស់សិស្ស។ ការវាយតម្លៃលើបំណិនសម្បទាមានដូចជា : ការប្រាស្រ័យទាក់ទង ការកំណត់គោលដៅ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ការធ្វើផែនការ ការចាត់ចែង ការគ្រប់គ្រងពេលវេលា ការគិតបែបពិចារណា ការមានហេតុផល ការងារជាក្រុម...។

- **ការអភិវឌ្ឍចរិយាសម្បទា**

ជាការវាយតម្លៃសិស្សដែលបានអភិវឌ្ឍតាមរយៈការសិក្សាមេរៀនបំណិនជីវិតមានលក្ខណៈអនុវត្តជាក់ស្ដែង ហើយឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ ការវាយតម្លៃលើចរិយាសម្បទាមានដូចជា : ការឱ្យតម្លៃលើខ្លួនឯង ភាពស្មោះត្រង់ ឥរិយាបថវិជ្ជមាន ការគ្រប់គ្រងកំហឹង ការទទួលខុសត្រូវ...។

**គោលការណ៍នៃការវាយតម្លៃ** ត្រូវបានកំណត់ជាពីរផ្នែក ការវាយតម្លៃចំណេះដឹង និងការវាយតម្លៃលើការងារប្រតិបត្តិ។

### ៦.១- ការវាយតម្លៃចំណេះដឹង

ជាការវាយតម្លៃលើសំណួរបញ្ចប់មេរៀន ដើម្បីពិនិត្យកម្រិតយល់ដឹងរបស់សិស្សលើខ្លឹមសារមេរៀន។ ការវាយតម្លៃសំណួរនេះផ្ដល់ពិន្ទុដល់សិស្ស៤០%នៃពិន្ទុសរុប១០។ ការវាយតម្លៃនេះក៏ដូចជាការវាយតម្លៃ ចំណេះដឹងលើមុខវិជ្ជាផ្សេងទៀតដែរ ដើម្បីយកពិន្ទុដាក់ក្នុងបណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ។ គ្រូអាចមើលគំរូខាងក្រោម ដើម្បីធ្វើការវាយតម្លៃលើសំណួរ និងកែកិច្ចការសិស្ស។ បន្ទាប់មកបម្លែងពិន្ទុ : ០-១ខ្សោយ ២-៣មធ្យម ៣.២៥-៤ល្អ ដើម្បីបញ្ចូលទៅក្នុងតារាងបូកសរុបវាយតម្លៃការសិក្សារបស់សិស្ស។

ខាងក្រោមនេះជាឧទាហរណ៍គំរូការវាយតម្លៃសម្រាប់មេរៀនបំណិនជីវិតផ្នែកសង្គម(អំពើហិង្សាក្នុងគ្រួសារ)។

**១. ចំណេះដឹងដែលទទួលបាន** (០១ពិន្ទុ)

ក. តើមូលហេតុអ្វីដែលបណ្ដាលឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ? (0.២៥ពិន្ទុ)

...........................................................................................................................

ខ. តើការកើតមានអំពើហិង្សាក្នុងគ្រួសារបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះ? (0.២៥ពិន្ទុ)

...........................................................................................................................

គ. តើប្អូនគួរធ្វើយ៉ាងដូចម្ដេចដើម្បីការពារកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ? (0.៥០ពិន្ទុ)

...........................................................................................................................

**២. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯង** (០១ពិន្ទុ)

តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីការពារខ្លួនអ្នកឱ្យចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

...........................................................................................................................

**៣. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារ និងសហគមន៍** (០២ពិន្ទុ)

តើប្អូនត្រូវធ្វើដូចម្តេចដើម្បីការពារគ្រួសារនិងសហគមន៍របស់អ្នកឱ្យចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

..........................................................................................................................

❖ គ្រូអាចរៀបចំការវាយតម្លៃសម្រាប់មេរៀនផ្សេងៗទៀត ដែលជាបំណិនបច្ចេកទេស (កសិកម្ម សិប្បកម្ម សេវាកម្ម) និងសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ។

## ៦.២- ការវាយតម្លៃការងារប្រតិបត្តិ

ការវាយតម្លៃនេះ គឺផ្តោតលើលទ្ធផលរំពឹងទុកដែលបានពីការងារប្រតិបត្តិផ្ទាល់របស់សិស្ស តាមកម្រិតថ្នាក់នីមួយៗ ជាបុគ្គល ក្រុម ឬជាការងារគម្រោង។ ការវាយតម្លៃការងារប្រតិបត្តិត្រូវបានផ្តល់ពិន្ទុជាបុគ្គល ឬជាក្រុមដែលមាន៦០%នៃពិន្ទុសរុប។ តាមរយៈសកម្មភាពនេះយើងអាចមើលឃើញសិស្សអភិវឌ្ឍបំណិនសម្បទា និងចរិយាសម្បទារបស់គេដែលនឹងត្រូវកត់ត្រាក្នុងតារាងខាងក្រោម។ (សិស្សប្រើទម្រង់ខាងក្រោមដើម្បីធ្វើស្វ័យវាយតម្លៃដោយប្រើខ្មៅដៃ ចំណែកគ្រូក៏ប្រើទម្រង់នេះដើម្បីវាយតម្លៃសិស្សម្នាក់ៗដែរ)។

ប្រធានបទ៖.....................................ឈ្មោះ...................................ភេទ..............................

ថ្នាក់..................ភូមិ............................................ឃុំ/សង្កាត់...........................................

ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង..........................................................................

☹ សមត្ថភាពមិនទាន់សម្រេចបាន

😐 សមត្ថភាពកំពុងទទួលបាន

☺ សមត្ថភាពទទួលបានពេញលេញ

| ល.រ | បំណិនដែលបានអភិវឌ្ឍ | ស្ថានភាព | | |
|---|---|---|---|---|
| | | ☹ **ខ្សោយ** | 😐 **មធ្យម** | ☺ **ល្អ** |
| **១** | **ការប្រាស្រ័យទាក់ទង :** ខ្ញុំបង្ហាញពីគោលបំណង និងគំនិតច្បាស់លាស់ ហើយបញ្ជាក់ឡើងវិញ។ ខ្ញុំតែងតែស្តាប់ដោយយកចិត្តទុកដាក់ ហើយមិនដែលមានទំនាស់ឡើយ។ | | | |
| ២ | **ការកំណត់គោលដៅ :** ខ្ញុំដឹងច្បាស់ពីអ្វីដែលខ្ញុំត្រូវធ្វើនៅពេលធំឡើង ហើយអំណត់ព្យាយាមដើម្បីសម្រេចគោលដៅនោះ។ | | | |

| | | | | |
|---|---|---|---|---|
| ៣ | **ការដោះស្រាយបញ្ហា :**<br>ខ្ញុំអាចកំណត់បានដំណោះស្រាយច្រើនចំពោះបញ្ហាមួយ ហើយរើសយកដំណោះស្រាយសមស្របដែលខ្ញុំអាចដោះស្រាយបាន។ | | | |
| ៤ | **ការសម្រេចចិត្ត :**<br>ខ្ញុំតែងតែប្រមូលព័ត៌មាន និងភស្តុតាងជាច្រើន ឬពិគ្រោះយោបល់ជាមួយអ្នកមានបទពិសោធមុននឹងធ្វើការសម្រេចចិត្ត។ | | | |
| ៥ | **ការធ្វើផែនការ :**<br>ខ្ញុំដឹងថាត្រូវធ្វើអ្វី? ហេតុអ្វី? ធ្វើពេលណា? ធនធានអ្វី? ធ្វើយ៉ាងដូម្តេច? | | | |
| ៦ | **ការគ្រប់គ្រងពេលវេលា** :<br>ខ្ញុំចេះប្រើប្រតិទិន ធ្វើផែនការប្រចាំថ្ងៃដើម្បីសម្រេចការងាររបស់ខ្ញុំ។ | | | |
| ៧ | **ការគិតបែបពិចារណា :**<br>ខ្ញុំតែងតែសួរខ្លួនឯងថា ប្រសិនបើខ្ញុំធ្វើដូចនេះ អ្វីនឹងកើតឡើង? តើមានជម្រើសផ្សេងទៀតដែលប្រសើរជាងនេះដែរឬទេ? | | | |
| ៨ | **ការមានហេតុផល :**<br>ខ្ញុំតែងសួររកហេតុផល អំណះអំណាង និងភស្តុតាងច្បាស់លាស់។ | | | |
| ៩ | **ការងារក្រុម :**<br>ខ្ញុំជាសមាជិកសកម្ម ស្តាប់យោបល់អ្នកដទៃ និងជួយនាំក្រុមឱ្យសម្រេចជោគជ័យ។ | | | |
| ១០ | **ការឱ្យតម្លៃលើខ្លួនឯង :**<br>ខ្ញុំគិតវិជ្ជមានពីខ្លួនឯង និងសាទរចំពោះជោគជ័យដែលខ្លួនធ្វើ។ | | | |
| ១១ | **ភាពស្មោះត្រង់ :**<br>ខ្ញុំតែងតែនិយាយពីការពិត ទទួលខុសត្រូវចំពោះអ្វីដែលខ្ញុំបានធ្វើ។ ទន្ទឹមនឹងនេះ ខ្ញុំតែងតែបញ្ចេញទស្សនៈរបស់ខ្ញុំចំពោះការពិតនោះ។ | | | |

| | | | | |
|---|---|---|---|---|
| ១២ | **ឥរិយាបថវិជ្ជមាន :**<br>ខ្ញុំមានចិត្ត និងគំនិតទូលំទូលាយ ឱ្យតម្លៃអ្នកដទៃ និងទទួលការរិះគន់ដោយរីករាយ។ គំនិតវិជ្ជមាន នាំឱ្យមាន ទង្វើវិជ្ជមាន នាំឱ្យមាន អារម្មណ៍វិជ្ជមាន ។ | | | |
| ១៣ | **ការយល់ចិត្តគ្នា :**<br>ខ្ញុំតែងតែដាក់ខ្លួនខ្ញុំក្នុងស្ថានភាពអ្នកដទៃ ហើយសួរខ្លួនឯងថា ប្រសិនបើខ្ញុំជាគាត់ តើខ្ញុំគួរធ្វើយ៉ាងណា? | | | |
| ១៤ | **ការគ្រប់គ្រងកំហឹង :**<br>ខ្ញុំតែងតែព្យាយាមយល់ពីបញ្ហាឱ្យបានច្បាស់ បន្ទាប់មករាប់ពី១ដល់១០ មុននឹងឆ្លើយតប។ ខ្ញុំក៏ព្យាយាមបង្ហាញពីហេតុផល ដើម្បីឱ្យដៃគូបានយល់ និងស្ងប់ចិត្ត។ | | | |
| ១៥ | **ការទទួលខុសត្រូវ :**<br>ខ្ញុំទទួលស្គាល់ការពិត និងកែលម្អចំណុចខ្វះខាតរបស់ខ្ញុំ។ | | | |
| ១៦ | **កម្រងស្នាដៃ :**<br>ឯកសាររបាយការណ៍ និងផលិតផល។ | | | |

តារាងខាងលើជាទម្រង់ណែនាំគ្រូ សម្រាប់ការវាយតម្លៃលទ្ធផលរំពឹងទុករបស់សិស្ស លើបំណិនសម្បទា និងចរិយាសម្បទាដែលបានអភិវឌ្ឍពីការរៀនមេរៀនបំណិនជីវិត។ សិស្សត្រូវបានវាយតម្លៃ និងកំណត់លំដាប់ពិន្ទុដូចខាងក្រោម៖

| ល.រ | កម្រិតសិក្សា | លំដាប់ពិន្ទុ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ខ្សោយ | មធ្យម | ល្អ | |
| ១ | បឋមសិក្សា | ១-២.៥ | ៣-៤ | ៤-៦ | |

# តារាងបូកសរុបវាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ប្រធានបទ៖.......................................................................................................ថ្នាក់.........................

ឈ្មោះ...............................................ភេទ..............................ភូមិ...................................................ឃុំ

/សង្កាត់....................................ស្រុក/ខណ្ឌ........................................ខេត្ត/ក្រុង..............................

☹ សមត្ថភាពមិនទាន់សម្រេចបាន

😐 សមត្ថភាពកំពុងទទួលបាន

☺ សមត្ថភាពទទួលបានពេញលេញ។

| ល.រ | ឈ្មោះសិស្ស | តេស្តចំណេះដឹង | | | តេស្តការងារប្រតិបត្តិ | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | វិជ្ជាសម្បទា | | | បំណិនសម្បទា | | | ចរិយាសម្បទា | | |
| | | ខ្សោយ ☹ | មធ្យម 😐 | ល្អ ☺ | ខ្សោយ ☹ | មធ្យម 😐 | ល្អ ☺ | ខ្សោយ ☹ | មធ្យម 😐 | ល្អ ☺ |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |
| ៥ | | | | | | | | | | |
| ៦ | | | | | | | | | | |
| ៧ | | | | | | | | | | |
| ៨ | | | | | | | | | | |
| ៩ | | | | | | | | | | |
| ១០ | | | | | | | | | | |
| ១១ | | | | | | | | | | |
| ១២ | | | | | | | | | | |
| ១៣ | | | | | | | | | | |
| ១៤ | | | | | | | | | | |
| ១៥ | | | | | | | | | | |
| ១៦ | | | | | | | | | | |
| ១៧ | | | | | | | | | | |

ថ្ងៃ........... ខែ.......... ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

............ ថ្ងៃទី.......... ខែ............... ឆ្នាំ២០១៨

គ្រូប្រចាំថ្នាក់

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- លទ្ធផលរំពឹងទុកថ្នាក់ទី៤

| សមាសភាព | លទ្ធផលរំពឹងទុក |
|---|---|
| **ជំពូកទី១. កសិកម្ម**<br>១- សួនជីវៈចម្រុះ<br>២- ដំណាំគ្រាប់<br>៣- ដំណាំត្រកួន<br>៤- ដំណាំផែថាវ<br>៥- ការចិញ្ចឹមមាន់ | **វិជ្ជាសម្បទា**<br>- ប្រាប់ការរៀបចំសួនជីវៈចម្រុះ ការដាំដំណាំ និងការចិញ្ចឹមសត្វ<br>- ប្រាប់ប្រភេទរុក្ខជាតិជាឱសថ រុក្ខជាតិលម្អ រុក្ខជាតិផ្តល់អាហារ<br>- ប្រាប់ផលប្រយោជន៍រុក្ខជាតិ បច្ចេកទេសនៃការដាំដំណាំ និងការចិញ្ចឹមសត្វបានត្រឹមត្រូវ<br>**បំណិនសម្បទា**<br>- ផ្សព្វផ្សាយចំណេះដឹង និងចែករំលែកបទពិសោធន៍នៃការដាំ និងការចិញ្ចឹមសត្វដល់សហគមន៍<br>- គ្រប់គ្រង និងសង្កេតតាមដាន ការដាំ និងចញ្ចឹមសត្វ<br>- អនុវត្តការដាំដុះ និងចិញ្ចឹមសត្វបានត្រឹមត្រូវ<br>- ដោះស្រាយបញ្ហា និងស្រាវជ្រាវបន្ថែមក្នុងការដាំដំណាំ និងចិញ្ចឹមសត្វ<br>- សរសេរចងក្រងឯកសារពីដំណើរការ និងលទ្ធផលការដាំ និងចិញ្ចឹម<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីឧស្សាហ៍ព្យាយាមអត់ធ្មត់ ទទួលខុសត្រូវ មានភាពក្លាហាន សហការក្នុងក្រុម<br>- បណ្តុះស្មារតីស្រឡាញ់ចូលចិត្តដាំដំណាំ និងចិញ្ចឹមសត្វ<br>- បង្កើនចំណូលសេដ្ឋកិច្ចក្នុងគ្រួសារតាមរយៈការដាំ និងចិញ្ចឹម<br>- បណ្តុះទម្លាប់ និងគំនិតស្រាវជ្រាវពីដំណាំ និងការចិញ្ចឹម |
| **ជំពូក២. សិប្បកម្មខ្នាតតូច**<br>១- សិប្បកម្មខ្នាតតូច<br>២- ការផលិតស្រោមសំបុត្រ និងថង់ក្រដាស<br>៣- ការផលិតផ្កា និងសត្វពីក្រដាស<br>៤- ការសូនរូបវត្ថុផ្សេងៗពីដីឥដ្ឋ | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ ប្រភេទសិប្បកម្មខ្នាតតូចបានត្រឹមត្រូវ<br>- ពណ៌នាពីសារប្រយោជន៍សិប្បកម្មខ្នាតតូច ការផលិតស្រោមសំបុត្រ ថង់ក្រដាស ផ្កា សត្វដែលធ្វើពីក្រដាស<br>- ប្រាប់ពីប្រភេទ ទំហំឬខ្នាតវត្ថុដែលត្រូវផលិតបានត្រឹមត្រូវ<br>- រៀបរាប់បានពីធនធាន វត្ថុធាតុដើម ក្នុងមូលដ្ឋានបម្រើដល់ផ្នែកសិប្បកម្មបានក្បោះក្បាយ<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ធនធានដែលមានក្នុងមូលដ្ឋាន សម្រាប់បម្រើដល់ការផលិត<br>- អនុវត្តការផលិតស្រោមសំបុត្រ ផ្កា សូនរូបបានត្រឹមត្រូវ |

| | |
|---|---|
| | - ស្រាវជ្រាវ បង្កើនការច្នៃប្រឌិត រចនាវត្ថុផ្សេងៗប្រកបដោយសោភណភាពដើម្បីទាក់ទាញ<br>- ផ្សព្វផ្សាយបទពិសោធន៍ដល់សហគមន៍<br>**ចរិយាសម្បទា**<br>- បណ្តុះទម្លាប់ទទួលខុសត្រូវ ឧស្សាហ៍ព្យាយាម និងមានស្មារតីសហការក្នុងក្រុម<br>- បង្កើនទម្លាប់ដោះស្រាយបញ្ហាប្រឈមបានសមស្រប<br>- បណ្តុះគំនិតច្នៃប្រឌិត និងមានស្មារតីប្រុងប្រយ័ត្ន<br>- បណ្តុះស្មារតីថែរក្សា ការពារបរិស្ថាន |
| **ជំពូក៣. សេវាកម្ម**<br>១- សេវាកម្ម<br>២- មុខទំនិញ<br>៣- តំណាប់ចេកហាល<br>៤- សណ្តាប់ធ្នាប់ក្នុងគេហដ្ឋាន និងក្នុងថ្នាក់រៀន<br>៥- ការបង្ហាញផ្លូវភ្ញៀវ | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ ប្រភេទសេវាកម្ម ទំនិញ បានក្បោះក្បាយ<br>- រៀបរាប់ផលប្រយោជន៍នៃសេវាកម្ម តំណាប់ចេក សណ្តាប់ ធ្នាប់ក្នុងគេហដ្ឋាន ថ្នាក់រៀន និងការបង្ហាញផ្លូវភ្ញៀវ បានក្បោះក្បាយ<br>- ពណ៌នាមុខទំនិញ និងតម្រូវការរបស់អតិថិជន<br>- រៀបរាប់ពីសណ្តាប់ធ្នាប់ក្នុងគេហដ្ឋាន ថ្នាក់រៀន និងរបៀបបង្ហាញផ្លូវភ្ញៀវ<br>**បំណិនសម្បទា**<br>- ផ្សព្វផ្សាយពីសុវត្ថិភាពចំណីអាហារ<br>- បង្ហាញពីសេវាកម្មផ្សេងៗដែលមាននៅក្នុងសហគមន៍<br>- បង្ហាញពីការទុកដាក់សម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងថ្នាក់រៀនឱ្យមានសណ្តាប់ធ្នាប់ល្អ<br>- អនុវត្តការធ្វើតំណាប់ចេក រៀបចំសណ្តាប់ធ្នាប់គេហដ្ឋាននិងថ្នាក់រៀន និងបង្ហាញផ្លូវភ្ញៀវបានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- បណ្តុះទម្លាប់នៃការប្រាស្រ័យទាក់ទង<br>- បង្កើនភាពស្និទ្ធស្នាល និងជួយផ្គុះគ្នាទៅវិញទៅមក<br>- បណ្តុះទម្លាប់ឱ្យមានសណ្តាប់ធ្នាប់ល្អក្នុងការរស់នៅប្រចាំថ្ងៃ |
| **ជំពូក៤. សហគ្រិនភាព និងភាពជាអ្នកដឹកនាំ**<br>១- ការសន្សំប្រាក់<br>២- ការប្រាស្រ័យទាក់ទង<br>៣- ធាតុផ្សំនៃចំណងមិត្តភាព<br>៤.-ការចង់បាន និងតម្រូវការ | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ ប្រភេទនៃការសន្សំ និងសារៈសំខាន់<br>- ប្រាប់ពីរបៀបប្រាស្រ័យទាក់ទង និងធាតុផ្សំនៃចំណងមិត្តភាព<br>- ប្រាប់ពីការចង់បាន និងតម្រូវការបានច្បាស់លាស់<br>**បំណិនសម្បទា**<br>- ដាក់ប្រាក់សន្សំជាក្រុមដោយមានការកត់ត្រាច្បាស់លាស់<br>- កំណត់ពីភាពខុសគ្នារវាងការចង់បាន និងតម្រូវការ |

| | |
|---|---|
| | - បង្កើតចំណងមិត្តភាពបានយូរអង្វែង<br>**ចរិយាសម្បទា**<br>- បណ្តុះទម្លាប់នៃការសន្សំជាបុគ្គល ឬជាក្រុម<br>- បណ្តុះទម្លាប់ នៃការប្រាស្រ័យទាក់ទង និងចំណងមិត្តភាព<br>- បណ្តុះទម្លាប់ចំណាយតាមតម្រូវការកំណត់ |
| **ជំពូក៥. បញ្ហាសង្គម**<br>១- ខ្ញុំជានរណា<br>២- ស្លាកសញ្ញាចរាចរណ៍<br>៣- ការលើកទឹកចិត្ត<br>៤- ការជួយមិត្ត<br>៥- អាហារូបត្ថម្ភ<br>៦- សិទ្ធិកុមារ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីខ្លួនឯងបានក្បោះក្បាយ<br>- រៀបរាប់បានពីអត្ថប្រយោជន៍នៃស្លាកសញ្ញាចរាចរណ៍ និងអាហារូបត្ថម្ភ<br>- ប្រាប់បានពីរបៀបលើកទឹកចិត្ត ការជួយមិត្ត និងការយល់ដឹងពីសិទ្ធិកុមារ<br>**បំណិនសម្បទា**<br>- បង្ហាញអត្ថន័យស្លាកសញ្ញាចរាចរណ៍បានច្បាស់លាស់<br>- កំណត់បាននូវប្រភេទអាហារូបត្ថម្ភសម្រាប់ទ្រទ្រង់រាងកាយ<br>- អនុវត្តនូវការលើកទឹកចិត្ត ការជួយមិត្ត និងការប្រើប្រាស់សិទ្ធិកុមារ<br>**ចរិយាសម្បទា**<br>- បណ្តុះទម្លាប់គោរពស្លាកសញ្ញាចរាចរណ៍<br>- បណ្តុះទម្លាប់បរិភោគអាហារដែលមានជីវជាតិគ្រប់គ្រាន់<br>- បណ្តុះស្មារតីក្នុងការលើកទឹកចិត្ត ការជួយមិត្ត និងការប្រើប្រាស់សិទ្ធិកុមារ |

### ៧.២- លទ្ធផលរំពឹងទុកថ្នាក់ទី៥

| សមាសភាព | លទ្ធផលរំពឹងទុក |
|---|---|
| **ជំពូក១. កសិកម្ម**<br>១- ការរៀបចំសួនជីវៈចម្រុះ<br>២- ជីកំប៉ុស្តគោក<br>៣- ជីកំប៉ុស្តទឹក<br>៤- ដំណាំម្រេះ<br>៥- ដំណាំពោត<br>៦- ដំណាំស្ពៃ<br>៧- ការចិញ្ចឹមជន្លេន | **វិជ្ជាសម្បទា**<br>- រៀបរាប់របៀបដាំ របៀបចិញ្ចឹម និងវិធីធ្វើជីកំប៉ុស្តបានច្បាស់លាស់<br>- រៀបរាប់ប្រភេទជំងឺ និងសត្វល្អិតចង្រៃ<br>- ប្រាប់ពីប្រភេទរុក្ខជាតិ និងសារប្រយោជន៍របស់រុក្ខជាតិនីមួយៗ បានត្រឹមត្រូវ(ជាឱសថ សម្រាប់លម្អ និងផ្តល់ជាអាហារ)<br>**បំណិនសម្បទា**<br>- ប្រមូលព័ត៌មានពីបច្ចេកទេសដាំ ការចិញ្ចឹម និងធ្វើជីកំប៉ុស្ត<br>- អនុវត្តការដាំដុះ ការចិញ្ចឹម ប្រកប ដោយប្រសិទ្ធភាពដើម្បីបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ<br>- ស្វែងរកតម្រូវការទីផ្សារ និងបត់បែនតាមតម្រូវការទីផ្សារ |

| | |
|---|---|
| | - ផ្សព្វផ្សាយចែករំលែកបទពិសោធន៍ ការដាំ ការចិញ្ចឹម និងការផលិតជីកំប៉ុស្តនៅក្នុងមូលដ្ឋាន<br>- ស្វែងយល់ពីមូលហេតុ ដោះស្រាយបញ្ហាដែលកើតមាន<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីឧស្សាហ៍ព្យាយាម អំណត់អត់ធ្មត់ ទទួលខុសត្រូវរាល់ការងារ<br>- បណ្ដុះស្មារតីចូលរួមកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន<br>- បង្កើនទម្លាប់ស្រាវជ្រាវពីការដាំ និងការចិញ្ចឹម<br>- បណ្ដុះស្មារតីសាមគ្គី សហការ មិនមានការរើសអើង និងមានទំនាក់ទំនងល្អ<br>- បណ្ដុះគំនិតត្រិះរិះ ពិចារណា ដោះស្រាយបញ្ហាក្នុងគ្រួសារ និងមូលដ្ឋាន |
| **ជំពូក២. សិប្បកម្មខ្នាតតូច**<br>១- ការផលិតប្រអប់ដាក់វត្ថុអនុស្សាវរីយ៍<br>២- ការផលិតទ្រនាប់កែវ និងចាន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីរបៀបផលិត ផលប្រយោជន៍ ប្រអប់ដាក់វត្ថុអនុស្សាវរីយ៍ ទ្រនាប់កែវ និងចាន<br>- រៀបរាប់បានពីធនធានក្នុងមូលដ្ឋានបម្រើដល់ផ្នែកសិប្បកម្ម<br>**បំណិនសម្បទា**<br>- ស្វែងយល់តម្រូវការ និងកែច្នៃ<br>- អនុវត្តបានការផលិតប្រអប់ដាក់វត្ថុអនុស្សាវរីយ៍ ទ្រនាប់កែវ និងចាន<br>- គ្រប់គ្រង សហការ ចាត់ចែងការងារក្រុម<br>- ចែករំលែកបទពិសោធ និងចូលរួមអភិវឌ្ឍផលិតផលក្នុងសហគមន៍<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីគាំទ្រផលិតផលក្នុងមូលដ្ឋាន<br>- បណ្ដុះស្មារតីម្ចាស់ការទទួលខុសត្រូវ ច្នៃប្រឌិត<br>- បណ្ដុះស្មារតីស្រឡាញ់ ព្យាយាមអត់ធ្មត់ក្នុងការងារ |
| **ជំពូក៣. សេវាកម្ម**<br>១- ជ្រក់សណ្ដែកបណ្ដុះ<br>២- ការលក់ទំនិញ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីវិធីធ្វើ និងសារប្រយោជន៍ជ្រក់សណ្ដែកបណ្ដុះ ប្រកបដោយគុណភាព អនាម័យ<br>- ប្រាប់ពីចំណូលចំណាយជ្រក់សណ្ដែកបណ្ដុះ<br>**បំណិនសម្បទា**<br>- ស្វែងរកព័ត៌មានទីផ្សារ និងការផ្គត់ផ្គង់<br>- អនុវត្តបានការធ្វើជ្រក់សណ្ដែកបណ្ដុះប្រកបដោយរសជាតិ និងអនាម័យ<br>- បង្ហាញ ផ្សព្វផ្សាយពីសុវត្ថិភាពចំណីអាហារ<br>- ច្នៃប្រឌិតរសជាតិ សោភណភាព ការវេចខ្ចប់បានប្រសើរ<br>- បញ្ចុះបញ្ចូលអតិថិជន និងស្វែងយល់ពីតម្រូវការអតិថិជន |

| | |
|---|---|
| | - ផ្តល់សេវាដល់អតិថិជន និងទាន់ពេលវេលា<br>- បង្កើតទំនាក់ទំនងល្អជាមួយអតិថិជន<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីឱ្យមានសុជីវធម៌ល្អ ឥរិយាបថល្អ និងទំនាក់ទំនងល្អជាមួយអតិថិជន<br>- បណ្តុះទម្លាប់មានអនាម័យ និងសុវត្ថិភាពចំណីអាហារ<br>- បណ្តុះគំនិតចាត់ចែង គ្រប់គ្រង បញ្ចុះបញ្ចូលអតិថិជន |
| **ជំពូក៤. សហគ្រិនភាព និង ភាពជាអ្នកដឹកនាំ**<br>១- ផែនការហិរញ្ញវត្ថុ<br>២- កម្ចីប្រាក់<br>៣- មូលដ្ឋានគ្រឹះនៃការបង្កើត មុខរបរ<br>៤- ផែនការផ្ទាល់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ និងសារប្រយោជន៍នៃការធ្វើផែនការហិរញ្ញវត្ថុ កម្ចីប្រាក់ មូលដ្ឋានគ្រឹះនៃការបង្កើតមុខរបរ និងការធ្វើផែនការផ្ទាល់ខ្លួន<br>**បំណិនសម្បទា**<br>- រៀបចំអនុវត្តផែនការហិរញ្ញវត្ថុងាយៗ<br>- សង្កេត តាមដាន និងកែតម្រូវនូវចំនុចខ្វះខាតលើផែនការ<br>- ស្វែងយល់ពីប្រភេទកម្ចីផ្សេងៗ និងមូលដ្ឋានគ្រឹះនៃការបង្កើត មុខរបរ<br>- សហការចែករំលែកបទពិសោធ<br>- ពិគ្រោះយោបល់នឹងអ្នកជំនាញ ដើម្បីដោះស្រាយបញ្ហា<br>- ញែកភាពខុសគ្នារវាងប្រភេទកម្ចីផ្សេងៗ<br>**ចរិយាសម្បទា**<br>- គ្រប់គ្រង និងចាត់ចែងធនធាន ទទួលខុសត្រូវចំពោះការងារ<br>- បណ្តុះស្មារតីសម្រេចចិត្តមុនទទួលប្រាក់កម្ចី<br>- ចែករំលែកព័ត៌មាន និងបទពិសោធ<br>- បណ្តុះទម្លាប់គ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន<br>- បណ្តុះស្មារតីក្នុងការធ្វើផែនការផ្ទាល់ខ្លួន និងអនុវត្តតាម ផែនការដែលបានធ្វើ |
| **ជំពូក៥. បញ្ហាសង្គម**<br>១- យេនឌ័រ<br>២- ការចងក្រងក្រុម<br>៣- ការពេញចិត្តចំពោះរាងកាយ របស់ខ្ញុំ<br>៤- ការស្តាប់ក្នុងការរៀន | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ តួនាទីយេនឌ័រ ការចងក្រងក្រុម ការពេញចិត្តចំពោះរាងកាយ ការស្តាប់ក្នុងការរៀន<br>- រៀបរាប់ពីសារៈសំខាន់នៃការស្តាប់ក្នុងការរៀន<br>- ប្រាប់ផលប៉ះពាល់នៃការរើសអើងយេនឌ័រក្នុងគ្រួសារ និងសង្គម<br>**បំណិនសម្បទា**<br>- ពន្យល់ពីការរើសអើង និងមិនរើសអើងរវាងស្រីនឹងប្រុស<br>- ពន្យល់ពីការសហការ និងការបើកចិត្តទូលាយក្នុងការទទួលយក និងកែលម្អ<br>- បញ្ឈប់ការរើសអើងក្នុងគ្រួសារ និងសង្គម |

| | |
|---|---|
| | - ជ្រើសរើសឱកាសសមស្រប និងសម្របខ្លួនទៅនឹងមជ្ឈដ្ឋានជុំវិញ<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីឱ្យមានបម្រុងប្រយត្ន និងទទួលខុសត្រូវ<br>- បណ្តុះស្មារតីស្មោះត្រង់ និងលើកទឹកចិត្ត<br>- ទំនុកចិត្ត ស្រឡាញ់ថែរក្សា និងការពារនូវអ្វីដែលខ្លួនមាន |

## ៧.៣- លទ្ធផលរំពឹងទុកថ្នាក់ទី៦

| **សមាសភាព** | **លទ្ធផលរំពឹងទុក** |
|---|---|
| **ជំពូក១. កសិកម្ម**<br>១- ដំណាំនទោង<br>២- ដំណាំសណ្តែកកួរ<br>៣- ដំណាំខ្ទឹមស្លឹក<br>៤- ការចិញ្ចឹមត្រី | **វិជ្ជាសម្បទា**<br>- ប្រាប់របៀបធ្វើគម្រោងដាំ និងចិញ្ចឹមបានច្បាស់លាស់<br>- រៀបរាប់ផលប្រយោជន៍នៃការដាំ និងការចិញ្ចឹមបានត្រឹមត្រូវ<br>- ប្រាប់ពីរបៀបប្រមូលផល និងវិធីរក្សាទុកឱ្យបានត្រឹមត្រូវ<br>**បំណិនសម្បទា**<br>- អនុវត្តការដាំ និងចិញ្ចឹមទទួលបានផលល្អ<br>- ផ្សព្វផ្សាយ ចែករំលែកបទពិសោធដល់សហគមន៍<br>- ដោះស្រាយរាល់បញ្ហាប្រឈម<br>**ចរិយាសម្បទា**<br>- បណ្តុះគំនិតស្រឡាញ់ចូលចិត្តក្នុងការដាំ និងការចិញ្ចឹម<br>- បណ្តុះស្មារតី ទទួលខុសត្រូវ សហការ ទំនាក់ទំនងល្អ<br>- បង្កើតគំនិតច្នៃប្រឌិត ស្រាវជ្រាវបច្ចេកទេសថ្មីៗ |
| **ជំពូក២. សិប្បកម្មខ្នាតតូច**<br>ការផលិតវត្ថុអនុស្សាវរីយ៍អំពីវល្លិ ស្លឹកត្នោត សំបកខ្យង ក្រដាសពណ៌ កំណាត់ | **វិជ្ជាសម្បទា**<br>- ប្រាប់ប្រភេទ ទំហំឬខ្នាត ទម្រង់វត្ថុដែលត្រូវផលិត និងផលប្រយោជន៍នៃការផលិតអនុស្សាវរីយ៍<br>- រៀបរាប់ពីធនធានវត្ថុធាតុដើមសម្រាប់ផលិតវត្ថុអនុស្សាវរីយ ក្នុងមូលដ្ឋានបម្រើដល់ផ្នែកសិប្បកម្មបានសព្វគ្រប់<br>- រៀបរាប់វិធីធ្វើវត្ថុអនុស្សាវរីយ៍បានក្បោះក្បាយ<br>**បំណិនសម្បទា**<br>- ជ្រើសរើសវត្ថុធាតុដើមបានត្រឹមត្រូវ<br>- ផលិតដោយភាពច្នៃប្រឌិត និងរចនាបានស្អាតល្អ<br>- បង្កើនទំនាក់ទំនងល្អក្នុងក្រុម ឬសហគមន៍<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីសហការ ទំនាក់ទំនង ទទួលខុសត្រូវ<br>- បណ្តុះគំនិតច្នៃប្រឌិត ប្រុងប្រយ័ត្ន ថែរក្សាបរិស្ថាន<br>- បណ្តុះស្មារតីគាំទ្រ និងលើកទឹកចិត្តប្រើប្រាស់ផលិតផលក្នុងស្រុក |

| | |
|---|---|
| **ជំពូក៣. សេវាកម្ម**<br>១- ប្រភេទទំនិញ និង សុពលភាពទំនិញ<br>២- ត្រីងៀត<br>៣- តំណាប់ស្វាយ<br>៤- តំណាប់អំពិល | **វិជ្ជាសម្បទា**<br>- ប្រាប់ប្រភេទនៃមុខទំនិញ និងសុពលភាពទំនិញ<br>- រៀបរាប់ពីវិធីធ្វើ និងសារប្រយោជន៍នៃការផ្តល់សេវា ត្រីងៀត តំណាប់ស្វាយ តំណាប់អម្ពិល មុខទំនិញប្រកប ដោយគុណភាព និងអនាម័យ<br>- ប្រាប់បានពីចំណូលចំណាយនៃការផ្តល់សេវា ត្រីងៀត តំណាប់ស្វាយ តំណាប់អម្ពិល<br>**បំណិនសម្បទា**<br>- បង្ហាញពីសុវត្ថិភាពចំណីអាហារដល់អតិថិជន<br>- ច្នៃប្រឌិតចំណីអាហារតាមតម្រូវការអតិថិជន<br>- ផ្សព្វផ្សាយបទពិសោធ ពីការផ្តល់សេវាកម្ម<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីសហការ ទំនាក់ទំនង ទទួលខុសត្រូវ<br>- បណ្តុះគំនិតច្នៃប្រឌិត និងប្រកបដោយស្មារតីប្រុងប្រយត្ន<br>- បណ្តុះភាពក្លាហាន ស្រឡាញ់ ថែរក្សាបរិស្ថាន និងមានសុជីវធម៌ល្អក្នុងការផ្តល់សេវា<br>- បណ្តុះគំនិតចាត់ចែងគ្រប់គ្រង និងបញ្ចុះបញ្ចូលអតិថិជន |
| **ជំពូក៤. សហគ្រិនភាព និង ភាពជាអ្នកដឹកនាំ**<br>១- គ្រឹះស្ថានធានាគារ និង មីក្រូហិរញ្ញវត្ថុ<br>២- កម្ចីប្រាក់(ត)<br>៣- ការសន្សំប្រាក់<br>៤- ចំណូល និងចំណាយ<br>៥- ផែនការការងារ<br>៦- ការរៀបចំផែនការសម្រាប់ អនាគត<br>៧- ការបង្កើតមុខរបរងាយៗ<br>៨- ការប្រាស្រ័យទាក់ទង | **វិជ្ជាសម្បទា**<br>- ប្រាប់ពីគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ<br>- រៀបរាប់របៀបធ្វើផែនការការងារ និងតម្រូវការចាំបាច់<br>- ប្រាប់ពីរបៀបគ្រប់គ្រង និងចាត់ចែង<br>- ប្រាប់ពីមូលដ្ឋានគ្រឹះ និងសារប្រយោជន៍នៃកិច្ចសន្យាកម្ចី<br>**បំណិនសម្បទា**<br>- បង្កើនឱកាសការងារស្វែងយល់និងពិភាក្សាជាមួយអ្នកជំនាញ<br>- ពិនិត្យ ពិចារណាបានច្បាស់លាស់មុននឹងកម្ចីប្រាក់<br>- កត់ត្រា និងគណនាចំណូលចំណាយបានត្រឹមត្រូវ<br>- ចាត់ចែង គ្រប់គ្រងអារម្មណ៍ បញ្ចុះបញ្ចូលអតិថិជន<br>- សរសេរកិច្ចសន្យាកម្ចីងាយៗ<br>**ចរិយាសម្បទា**<br>- បណ្តុះទម្លាប់គោរពកិច្ចសន្យា និងទទួលខុសត្រូវ<br>- បណ្តុះទម្លាប់ស្មោះត្រង់ ឧស្សាហ៍ព្យាយាម អត់ធ្មត់ និងប្រុងប្រយត្ន<br>- បណ្តុះស្មារតីសហការ ទំនាក់ទំនង បង្កើនភាពស្និទ្ធស្នាលជាមួយសហគមន៍ |
| **ជំពូក៥. បញ្ហាសង្គម**<br>១- អំពើហិង្សាក្នុងគ្រួសារ<br>២- បំណុលវ័ណ្ឌក | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីមូលហេតុនិងវិធីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ បំណុលវ័ណ្ឌក គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះមហន្តរាយ |

| | |
|---|---|
| ៣- គ្រឿងញៀន<br>៤- គ្រោះថ្នាក់ចរាចរណ៍<br>៥- គ្រោះមហន្តរាយ | - ប្រាប់ពីបញ្ហាដែលកើតឡើងជុំវិញមជ្ឈដ្ឋានរស់នៅ<br>- ប្រាប់ពីរបៀបបង្កើតក្រុមបណ្ដាញតាមដាន<br>**បំណិនសម្បទា**<br>- បង្កើតយុទ្ធនាការផ្សព្វផ្សាយអប់រំពីអំពើហិង្សាក្នុងគ្រួសារ បំណុលវ័ណ្ឌក គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ គ្រោះមហន្តរាយ<br>- បង្កើតក្រុមមិត្តអប់រំមិត្ត<br>- បង្កើតបណ្ដាញពិនិត្យតាមដាននិងផ្ដល់ព័ត៌មាន<br>- កំណត់ពីមូលហេតុដោះស្រាយបញ្ហាដែលកើតមាន<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់ធ្វើកិច្ចការមានប្រយោជន៍ក្នុងសង្គម<br>- បណ្ដុះគំនិតពិចារណា ដោះស្រាយបញ្ហា ទទួលខុសត្រូវ ទំនាក់ទំនងក្នុងមូលដ្ឋាន<br>- បណ្ដុះស្មារតីសហការ ចែករំលែកធនធាន និងពេលវេលា |

## ៧.៤- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៤

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១. កសិកម្ម** | | **៣៥ម៉** |
| **មេរៀនទី១ សួនជីវៈចម្រុះ**<br>១- ការជ្រើសរើសប្រភេទរុក្ខជាតិ<br>២- ការរៀបចំដី<br>៣- ការដាំ<br>៤- ការថែទាំ<br>៥- ផលប្រយោជន៍ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការរៀបចំសួនជីវៈចម្រុះ<br>- ប្រាប់ប្រភេទរុក្ខជាតិ ជាឱសថ លម្អ ផ្ដល់អាហារ<br>- ប្រាប់ផលប្រយោជន៍នៃប្រភេទរុក្ខជាតិនីមួយៗ<br>**បំណិនសម្បទា**<br>- ធ្វើគម្រោងសួនជីវៈចម្រុះ<br>- អនុវត្តការដាំដុះ និងថែទាំ<br>- រៀបចំកែលម្អសោភណភាព<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីស្រឡាញ់ ចូលចិត្តរុក្ខជាតិ<br>- បណ្ដុះស្មារតីសហការ ទំនាក់ទំនង និងភាពក្លាហាន | |
| **មេរៀនទី២ ដំណាំគ្រាប់**<br>១- ការជ្រើសរើសដី<br>២- ការរៀបចំដី<br>៣- ការបណ្ដុះគ្រាប់<br>៤- ការដាំ<br>៥- ការថែទាំ<br>៦- ជំងឺ និងសត្វល្អិតចង្រៃ | **វិជ្ជាសម្បទា**<br>- រៀបរាប់របៀបបណ្ដុះគ្រាប់<br>- រៀបរាប់របៀបដាំ និងប្រមូលផល<br>- រៀបរាប់ប្រភេទជំងឺ និងសត្វល្អិតចង្រៃ<br>- ប្រាប់ផលប្រយោជន៍<br>**បំណិនសម្បទា**<br>- រៀបចំគម្រោងដាំ | |

| | | |
|---|---|---|
| ៧- ការប្រមូលផល<br>៨- ផលប្រយោជន៍ | - ជ្រើសរើសទីតាំង និងពូជ<br>- រៀបចំដី និងរង<br>- អនុវត្តការដាំ ការពារ ថែទាំ និងប្រមូលផល<br>- សង្កេត តាមដាន កត់ត្រាការលូតលាស់<br>- សរសេរ ចងក្រងឯកសារស្នាដៃដែលបានអនុវត្ត<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីទទួលខុសត្រូវ ឧស្សាហ៍ព្យាយាម និងសហការ<br>- បណ្ដុះគំនិតស្រឡាញ់ ចូលចិត្តការដាំដុះ | |
